**កម្មវិធីប្រជុំ អិលខែប នឹងបើកទទួលនៅ ថ្ងៃទី20 ខែតុលា**

ក្រសួងអប់រំ ឱស្រ្ទីគ Long Beach នឹងបើកផ្តល់កម្មវិធីប្រជុំពិសេសមួយស្តីអំពីគំរោងកិច្ចការគ្រប់គ្រង និង ទទួលខុសត្រូវប្រចាំតំបន់ (អិលខែប) សំរាប់ក្រុមសាធារណជនចូលរួមនៅ ថ្ងៃសៅរ៍ ទី20 ខែតុលា, ម៉ោង 8:00 ព្រឹក ទៅ 1:00 រសៀល នៅសាលារៀន Cabrillo High School – 2001 Santa Fe Avenue, Long Beach ។

កម្មវិធីនេះនឹងជួយមាតាបិតា និង សមាជិកក្នុងសហគមន៍រៀនអំពីភាពលូតលាស់នៅតាមក្រសួងអប់រំ ឱស្រ្ទីគ ក្នុងការជួយបំរុងសិស្សទាំងអស់ទៅរៀននៅមហាវិទ្យាល័យ និង ងាយចេញរកការងារធ្វើ ដែលមានទាំងការបង្ហាញពត៌មានផងអំពីមធ្យោបាយបង្កើតសមត្ថភាពនៃសិស្សទាំងអស់ឲ្យរៀនកាន់តែស្មើកំរិតគ្នា ។ កម្មវិធីក៏បង្កើតឱកាសផងដែរសំរាប់ក្រសួងអប់រំ ឱស្រ្ទីគ រៀនយោគយល់បន្ថែម និង ធ្វើការពិគ្រោះឆ្លងឆ្លើយជាមួយសិស្ស មាតាបិតា និង ក្រុមរួមចំណែកផ្សេងៗនៅក្នុងសហគមន៍ ។ អ្នកចូលរួមនឹងបានទទួលឱកាសសំរាប់ធ្វើការសើរើមើល និង ធ្វើការសិក្សាអំពីពត៌មានផ្សេងៗ ដែលលើកបង្ហាញដោយក្រសួងអប់រំ ឱស្រ្ទីគ ។ បន្ទាប់ទៅ ពួកគេអាចលើកផ្តល់ជាគោលយោបល់តបទៅវិញអំពីការរៀបចំជាគំរោងការណ៍ អិលខែប ។

ពេលវេលាព្រាងទុកសំរាប់កម្មវិធីប្រជុំប្រចាំថ្ងៃ:

| | |
|---|---|
| 8:00 – 9:00 | អាហារពេលព្រឹក/ការចុះឈ្មោះ |
| 9:00 – 10:15 | ការជួបជុំគ្នាក្នុងបន្ទប់ធំ |
| 10:25 – 11:25 | ការបំបែកទៅតាមបន្ទប់សំរាប់ធ្វើការសិក្សា |
| 11:35 – 12:00 | ការបិទបញ្ចប់កម្មវិធី/ការចែកផ្តល់អាហារថ្ងៃត្រង់ |
| 12:00 – 1:00 | ពេលទទួលអាហារថ្ងៃត្រង់ |

កម្មវិធីប្រជុំ អិលខែប ជាសាធារណៈ គឺជាមធ្យោបាយបន្ថែមម៉្យាង ដែលក្រសួងអប់រំ ឱស្រ្ទីគ បើកទំនាក់ទំនងជាមួយក្រុមរួមចំណែកផ្សេងៗ ដើម្បីបង្កើតជាគំរោងការណ៍ ។ សំរាប់ពត៌មានបន្ថែម សូមអានមើលនៅតាម www.lbschools.net ។